**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខៈ** ១៣៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការទទួលស្គាល់សាកលវិទ្យាល័យគ្រប់គ្រងអាស៊ីបូព៌ា

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី៣១ ខែមីនា ឆ្នាំ២០០៣ ស្តីពីការទទួលស្គាល់គុណភាពអប់រំឧត្តមសិក្សា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ១៥៦ អនក្រ.បក ចុះថ្ងៃទី១៨ ខែកក្កដា ឆ្នាំ២០១៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ១១៦ អនក្រ.បក ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃទីស្តីការគណៈរដ្ឋមន្ត្រី
- បានឃើញអនុក្រឹត្យលេខ៥៤ អនក្រ.បក ចុះថ្ងៃទី១៣ ខែមិថុនា ឆ្នាំ២០០២ ស្តីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ
- បានឃើញអនុក្រឹត្យលេខ១៥៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែមីនា ឆ្នាំ២០១៤ ស្តីពីក្របខ័ណ្ឌគុណវុឌ្ឍិជាតិកម្ពុជា
- យោងតាមសំណើរបស់រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

## សម្រេច

**មាត្រា១.-**

ត្រូវបានទទួលស្គាល់គ្រឹះស្ថានឧត្តមសិក្សាឯកជនមួយ ដែលមានឈ្មោះថា " **សាកលវិទ្យាល័យគ្រប់គ្រងអាស៊ីបូព៌ា** " សរសេរជាអក្សរកាត់ថា " **ស.គ.អ.ប.** " និងជាភាសាអង់គ្លេសថា " East Asia Management University " សរសេរជាអក្សរកាត់ថា " E.A.M.U. "។



www.pheakdeylaw.com

**មាត្រា២.-**

សាកលវិទ្យាល័យគ្រប់គ្រងអាស៊ីប៉ូតាំ ស្ថិតនៅក្រោមអាណាព្យាបាលរបស់ក្រសួងអប់រំ យុវជន និងកីឡា និងមានទីតាំងស្ថិតនៅផ្លូវលេខ៧០ ភូមិទួលសង្កែ សង្កាត់ទួលសង្កែ ខណ្ឌឫស្សីកែវ រាជធានីភ្នំពេញ ។

**មាត្រា៣.-**

សាកលវិទ្យាល័យគ្រប់គ្រងអាស៊ីប៉ូតាំ ធ្វើការបណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ លើមហាវិទ្យាល័យចំនួន៥ និងមានសាលាក្រោយបរិញ្ញាបត្រ ព្រមទាំងមជ្ឈមណ្ឌលបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ ដែលមានរចនាសម្ព័ន្ធ និងមុខជំនាញ ដូចខាងក្រោម៖

**១- មហាវិទ្យាល័យសិល្បៈ មនុស្សសាស្ត្រ ភាសា និងអប់រំ**

បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ លើដេប៉ាតឺម៉ង់ និងមុខជំនាញដូចខាងក្រោម៖

- ដេប៉ាតឺម៉ង់អក្សរសាស្ត្រខ្មែរ៖ មុខជំនាញអក្សរសាស្ត្រខ្មែរ
- ដេប៉ាតឺម៉ង់ភាសាអង់គ្លេស៖ មុខជំនាញភាសាអង់គ្លេសធុរកិច្ច និងមុខជំនាញការបង្រៀនភាសាអង់គ្លេស
- ដេប៉ាតឺម៉ង់អប់រំ៖ មុខជំនាញការអប់រំកុមារតូច មុខជំនាញការអប់រំបឋមសិក្សា មុខជំនាញការអប់រំមធ្យមសិក្សា និងមុខជំនាញការអប់រំឧត្តមសិក្សា ។

**២- មហាវិទ្យាល័យវិទ្យាសាស្ត្រសង្គម និងសេដ្ឋកិច្ច**

បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ លើដេប៉ាតឺម៉ង់ និងមុខជំនាញដូចខាងក្រោម៖

- ដេប៉ាតឺម៉ង់ចិត្តវិទ្យា៖ មុខជំនាញចិត្តវិទ្យា
- ដេប៉ាតឺម៉ង់សេដ្ឋកិច្ច៖ មុខជំនាញសេដ្ឋកិច្ច
- ដេប៉ាតឺម៉ង់ច្បាប់៖ មុខជំនាញច្បាប់ ។

**៣- មហាវិទ្យាល័យវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា**

បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ លើដេប៉ាតឺម៉ង់ និងមុខជំនាញដូចខាងក្រោម៖

- ដេប៉ាតឺម៉ង់ប្រព័ន្ធព័ត៌មានវិទ្យាធុរកិច្ច៖ មុខជំនាញប្រព័ន្ធព័ត៌មានវិទ្យាធុរកិច្ច
- ដេប៉ាតឺម៉ង់បណ្តាញ Networks៖ មុខជំនាញកុំព្យូទ័រ និងបណ្តាញ
- ដេប៉ាតឺម៉ង់ការរចនា និងវិភាគប្រព័ន្ធ៖ មុខជំនាញការរចនា និងវិភាគប្រព័ន្ធ ។

**៤- មហាវិទ្យាល័យធុរកិច្ច និងគ្រប់គ្រង**

បណ្តុះបណ្តាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ លើដេប៉ាតឺម៉ង់ និងមុខជំនាញដូចខាងក្រោម៖

- ដេប៉ាតឺម៉ង់គ្រប់គ្រងធុរកិច្ចអន្តរជាតិ៖ មុខជំនាញធុរកិច្ចអន្តរជាតិ
- ដេប៉ាតឺម៉ង់គ្រប់គ្រងធុរកិច្ច៖ មុខជំនាញគ្រប់គ្រងធុរកិច្ច
- ដេប៉ាតឺម៉ង់គ្រប់គ្រងភស្តុភារ និងបណ្តាញផ្គត់ផ្គង់៖ មុខជំនាញគ្រប់គ្រងភស្តុភារ និងបណ្តាញផ្គត់ផ្គង់
- ដេប៉ាតឺម៉ង់គណនេយ្យ ៖ មុខជំនាញគណនេយ្យ
- ដេប៉ាតឺម៉ង់ធនាគារ និងហិរញ្ញវត្ថុ៖ មុខជំនាញធនាគារ និងហិរញ្ញវត្ថុ មុខជំនាញគណនេយ្យ និងហិរញ្ញវត្ថុ
- ដេប៉ាតឺម៉ង់ទីផ្សារ៖ មុខជំនាញទីផ្សារ ។



www.pheakdeylaw.com

**៥- មហាវិទ្យាល័យគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច**

បណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ លើដេប៉ាតឺម៉ង់ និងមុខជំនាញដូចខាងក្រោម៖

- ដេប៉ាតឺម៉ង់គ្រប់គ្រងទេសចរណ៍៖ មុខជំនាញគ្រប់គ្រងទេសចរណ៍ និងបដិសណ្ឋារកិច្ច
- ដេប៉ាតឺម៉ង់គ្រប់គ្រងបដិសណ្ឋារកិច្ច៖ មុខជំនាញគ្រប់គ្រងព្រឹត្តិការណ៍ និងសន្និសីទ មុខជំនាញគ្រប់គ្រងកាស៊ីណូ
- ដេប៉ាតឺម៉ង់ការរៀបចំចំណីអាហារ៖ មុខជំនាញការសិក្សាអំពីចំណីអាហារនិងការចម្អិន ។

**៦- សាលាក្រោយបរិញ្ញាបត្រ**

- មុខជំនាញរដ្ឋបាលធុរកិច្ច៖ បណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់
- មុខជំនាញធុរកិច្ចអន្តរជាតិ៖ បណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់
- មុខជំនាញគ្រប់គ្រងធនធានមនុស្ស៖ បណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់
- មុខជំនាញទីផ្សារ៖ បណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់
- មុខជំនាញហិរញ្ញវត្ថុ៖ បណ្ដុះបណ្ដាលកម្រិតបរិញ្ញាបត្រជាន់ខ្ពស់
- មុខជំនាញគ្រប់គ្រងធុរកិច្ច៖ បណ្ដុះបណ្ដាលកម្រិតបណ្ឌិត ។

**៧- មជ្ឈមណ្ឌលបណ្ដុះបណ្ដាលបច្ចេកទេស និងវិជ្ជាជីវៈ**

ទៅអនាគតសាកលវិទ្យាល័យនេះ អាចបើកសាខា មហាវិទ្យាល័យថ្មី ដេប៉ាតឺម៉ង់ថ្មី មុខជំនាញថ្មី កម្រិតបណ្ដុះបណ្ដាលថ្មី រៀបចំរចនាសម្ព័ន្ធមហាវិទ្យាល័យ សុំប្ដូរឈ្មោះថ្មី ទីតាំងថ្មី ឬពង្រីកទីតាំងថ្មី ដោយរៀបចំសំណុំបែបបទសុំការអនុញ្ញាតពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៤.-**

សាកលវិទ្យាល័យគ្រប់គ្រងអាស៊ីប៉ូព៌ា ត្រូវមានក្រុមប្រឹក្សាភិបាលមួយ ដើម្បីត្រួតពិនិត្យនិងសម្រេចលើគោលនយោបាយ ផែនការអភិវឌ្ឍកម្មវិធីសិក្សា និងការងារបច្ចេកទេសពាក់ព័ន្ធដទៃទៀត។ តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធចាត់តាំងជាក់ស្ដែងនៃសាកលវិទ្យាល័យគ្រប់គ្រងអាស៊ីប៉ូព៌ា ត្រូវកំណត់ដោយក្រុមប្រឹក្សាភិបាល និងមានការឯកភាពពីក្រសួងអប់រំ យុវជន និងកីឡា។

**មាត្រា៥.-**

សាកលវិទ្យាធិការ សាកលវិទ្យាល័យគ្រប់គ្រងអាស៊ីប៉ូព៌ា មានភារកិច្ច ដូចខាងក្រោម៖

- ទទួលខុសត្រូវចំពោះមុខច្បាប់ក្នុងការគ្រប់គ្រងសាកលវិទ្យាល័យគ្រប់គ្រងអាស៊ីប៉ូព៌ា និងធានាឱ្យមានសុវត្ថិភាព និងសណ្ដាប់ធ្នាប់សង្គម
- ទទួលខុសត្រូវក្នុងការទទួលសិស្ស និស្សិតឱ្យចូលរៀន និងការបញ្ចប់ការសិក្សា ស្របតាមបទដ្ឋានកំណត់របស់ក្រសួងអប់រំ យុវជន និងកីឡា
- រៀបចំបង្កើតថ្នាក់ឆ្នាំសិក្សាមូលដ្ឋាន ដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ជាមុនសិន មុននឹងជ្រើសរើសនិស្សិតចូលរៀនឆ្នាំទីមួយ កម្រិតបរិញ្ញាបត្រ
- រៀបចំកម្មវិធីសិក្សាលម្អិតឱ្យស្របតាមលក្ខខណ្ឌនិងបទប្បញ្ញត្តិនៃក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា



www.pheakdeylaw.com

- គោរពនិងអនុវត្តតាមបទដ្ឋាននិងគោលការណ៍ណែនាំរបស់ក្រសួងអប់រំ យុវជន និងកីឡា ដែលកំណត់លើសកម្មភាពនៃការធានាគុណភាពអប់រំឧត្តមសិក្សា
- ធ្វើរបាយការណ៍ប្រចាំឆ្នាំអំពីការងារបណ្តុះបណ្តាល ជូនក្រសួងអប់រំ យុវជន និងកីឡា នៅក្រោយដំណាច់ឆមាសទី២។

**មាត្រា៦.-**

និស្សិតនៃសាកលវិទ្យាល័យគ្រប់គ្រងអាស៊ីបូព៌ា ដែលបានរៀនចប់កម្មវិធីសិក្សា ហើយបានទទួលជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិតនិងឯកទេសដែលបានសិក្សា។ សញ្ញាបត្រនេះត្រូវផ្តល់ឱ្យដោយសាកលវិទ្យាល័យគ្រប់គ្រងអាស៊ីបូព៌ា ដោយផ្អែកលើបញ្ជីឈ្មោះនិស្សិតបញ្ចប់ការសិក្សាជាប់ជាស្ថាពរដែលមានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា៧.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៨.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នពាក់ព័ន្ធ និងសាកលវិទ្យាធិការនៃសាកលវិទ្យាល័យគ្រប់គ្រងអាស៊ីបូព៌ា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃអង្គារ ៦រោច ខែ អស្សុជ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី៣០ ខែ តុលា ឆ្នាំ២០១៨

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល៖**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- សាលារាជធានីភ្នំពេញ
- ដូចមាត្រា៨
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ



www.pheakdeylaw.com